# ថ្ងៃ១០ធ្នូ...

ដោយៈ អាចម៍ផ្កាយ

ថ្ងៃ១០ធ្នូ ជាថ្ងៃកំណើតរបស់**ខេមា** ជាថ្ងៃដែលនាងរៀបអាពាហ៍ពិពាហ៍ និងជាថ្ងៃកំណើតរបស់**ខេមរិទ្ធ** កូនប្រុសសំណព្វចិត្តតែមួយគត់របស់នាង។ ចាប់តាំងពីថ្ងៃដែល**ខេមរិទ្ធ** កើតរហូតដល់ថ្ងៃនេះ គ្មានរឿងអ្វីដែលធ្វើឲ្យ**ខេមា**សោកស្ដាយ ស្មើនឹងការបាត់បង់ជីវិតរបស់ប៉ា**ខេមរិទ្ធ** អ្នកដែលធ្លាប់រួមសុខរួមទុក្ខជាមួយគ្នា មករហូត២១ឆ្នាំនោះឡើយ។ នៅពេលនោះ **ខេមរិទ្ធ**មានអាយុ ២០ឆ្នាំ គេទើបតែបញ្ចប់ថ្នាក់បរិយាប័ត្រ ផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។

ពេលប៉ារបស់គេស្លាប់ **ខេមរិទ្ធ**បានប្ដេជ្ញាចិត្តប្រាប់ម៉ាក់របស់គេថា គេនឹងខិតខំធ្វើការ ហើយនឹងរៀនបន្តទៀត ប្រសិនណាមានឱកាស។ គេនឹងមិនធ្វើឲ្យម្ដាយត្រូវហត់នឿយ ដោយសារគេទៀតទេ។ ថ្មីៗនេះ**ខេមរិទ្ធ**ក៏បានចូលបម្រើការងារ ជាលេខាផ្នែកគណនេយ្យ ក្នុងក្រុមហ៊ុនតែមួយ ដែលប៉ារបស់គេធ្លាប់ធ្វើ និងដែលម៉ាក់របស់គេកំពុងធ្វើរាល់ថ្ងៃ។ នៅក្នុងក្រុមហ៊ុនបុគ្គលិកជាច្រើន ដែលជិតដិតនឹងម៉ាក់របស់**ខេមរិទ្ធ** ចូលចិត្តនិយាយបង្អាប់លេង ជារឿយៗ ៖

«**រិទ្ធ**អ្ហា!... ស្រីស្អាតដែលអង្គុយ នៅផ្នែកទំនាក់ទំនងនោះ បើឯងមិនញ៉ែ គ្នាសុំញ៉ែហើយ។» **ខេមរិទ្ធ**ដឹងយ៉ាងច្បាស់ថា ស្រីស្អាតដែលគេនិយាយនោះ គឺចង់សំដៅលើម្ដាយរបស់ខ្លួន។ កំលោះចូលចិត្តញញឹមតបទៅវិញ ដោយឥតប្រកាន់ ៖

«ចង់ញ៉ែ ក៏ញ៉ែចុះ! តែប្រយ័ត្នសង្ក្រាគាត់ មករករឿង ខ្ញុំជួយមិនបានទេ!...»

**ខេមា**ជាមនុស្សដែលមានគំនិតទូលាយ នាងអាចចូលចុះជាមួយសង្គមក្រុមមនុស្សចំរុះគ្រប់បែប និងអាចសម្របខ្លួនបានយ៉ាងឆាប់រហ័ស ជាមួយសង្គមខាងក្រៅ។ នាងយល់ជានិច្ចប្រសិនបើ កូននាងត្រឡប់មកផ្ទះវិញយប់ ហើយនាងតែងតែត្រៀមអាហារទុក សម្រាប់កូនមិនដែលខាន។ ទន្ទឹមនឹងនេះ **ខេមា**តែងតែតាមដានកូនរហូត ថាកូនទៅណា ជាមួយអ្នកណា? នាងមានលេខទូរស័ព្ទមិត្តភក្តិ របស់**ខេមរិទ្ធ**គ្រប់ៗគ្នា មិនថាមិត្តនៅកន្លែងធ្វើការ ឬមិត្តដែលធ្លាប់រៀនជាមួយគ្នានោះទេ។ និយាយឲ្យងាយយល់ ទោះបីនាងប្រគល់ឥស្សរភាព ទៅឲ្យកូនហើយក៏ដោយ ក៏ក្នុងក្រសែភ្នែករបស់នាង មានរូបកូនជាប់ជានិច្ច។ ចំពោះ**ខេមរិទ្ធ**ប្រសិនបើគេត្រូវចេញទៅក្រៅ ជាមួយមិត្តភក្តិម្ដងៗ គេក៏តែងប្រាប់ម៉ាក់របស់គេជាមុនគ្រប់ៗពេល ថានឹងទៅណា ជា

*មួយអ្នកណា។ អ្វីដែលសំខាន់ គឺគេមិនធ្លាប់មានរឿងណាមួយ ដែលធ្វើឲ្យម្ដាយពិបាកចិត្តឡើយ។*

*ប្រហែលជាមកពី**ខេមា** ចូលចុះជាមួយមិត្តរបស់កូនបានស្រួល ទើបធ្វើឲ្យមិត្តភក្តិគ្រប់ៗគ្នារបស់**ខេមរិន្ទ** គោរពនិងប្រតិបត្តិតាមនាងប្រាប់គ្រប់យ៉ាង រហូតអាចនិយាយបានថា «មិត្តរបស់កូន ក៏ដូចជាមិត្តរបស់ម៉ាក់»។ ដល់យូរៗទៅ ម៉ាក់របស់**ខេមរិន្ទ** ក៏ក្លាយជាគ្រូម្នាក់ដ៏ល្អសម្រាប់ពួកគេ ព្រោះនាងបានបង្រៀនអ្នកទាំងនោះ ឲ្យក្លាយជាមនុស្សល្អបាន នៅក្នុងលំដាប់មួយគួរជាទីពេញចិត្ត។ អ្វីដែលសំខាន់មួយទៀតនោះគឺ **ខេមា**ពេញចិត្តនឹងសមត្ថភាព រួមទាំងអ្វីៗជាច្រើនទៀត ដែលកូននាងអាចធ្វើបាន។ នាងមិនធ្លាប់គិតប្រាថ្នា ចង់ឲ្យកូនរបស់នាងត្រូវតែល្អឥតខ្ចោះ ឬជាមនុស្សដែលពូកែដាច់គេ អាចធ្វើអ្វីៗបានគ្រប់យ៉ាង គ្មានអ្នកប្រៀបនោះទេ។ នាងមានតែបង្រៀនថា «បើថ្ងៃនេះធ្វើបានល្អហើយ ថ្ងៃស្អែកត្រូវព្យាយាមធ្វើ ឲ្យបានល្អជាងនេះទៀត»។*

*រឿងមួយដែលគ្រប់គ្នាតែងលួចច្រណែននឹង**ខេមរិន្ទ**រហូតមក គឺ**ខេមរិន្ទ**តែងបានទទួលកាដូថ្ងៃកំណើតពីម្ដាយរាល់ៗឆ្នាំ តាំងពីតូចៗមក។ ក្នុងឱកាសបុណ្យខួបកំណើតគម្រប់អាយុ២០ឆ្នាំ គេបានទទួលកាដូជាសៀវភៅកំណត់ហេតុតូចមួយក្បាល។ កាលនោះ**ខេមា**ប្រាប់**ខេមរិន្ទ**ថា ៖*

*«កូនត្រូវរក្សាសៀវភៅមួយក្បាលនេះទុក ហើយប្រើសម្រាប់សរសេររឿងរ៉ាវសំខាន់ៗដែលមានន័យនៅក្នុងជីវិតរបស់កូន ហើយកូនអាចប្រគល់សៀវភៅនេះ ដល់មនុស្សដែលកូនស្រឡាញ់បាន នៅពេលណាដែលកូនបានភពប្រសព្វនឹងគេ។»*

*«កុំប្រញាប់អាន៣ទំព័រដំបូង ដែលបិទទុកអី ចាំដល់ថ្ងៃដែលកូនរៀបការសិន សឹមអាន។» ប៉ារបស់គេនិយាយ បន្ទាប់ពីខេមាបញ្ចប់សម្ដី។*

***ខេមរិន្ទ**ធ្លាប់សួរម្ដាយថា «ថ្ងៃកំណើតរបស់ម៉ាក់គឺថ្ងៃណា?» ចម្លើយដែលកំលោះទទួលបានគឺ «ថ្ងៃតែមួយជាមួយកូននេះហើយ!»។ ហើយពេលសួរថា «ម៉ាក់ចង់បានអី ជាកាដូថ្ងៃកំណើត?» ម្ដាយគេតែងតបមកវិញថា «បានឃើញកូនធំឡើង ថែមមួយឆ្នាំទៀត ក៏គ្រប់គ្រាន់ណាស់ទៅហើយ!»។ ទាក់ទងនឹងរឿងនេះ **ខេមរិន្ទ**នៅតែនឹកឆ្ងល់ជាប់ជានិច្ច រហូតមកដល់សព្វថ្ងៃ «តើម្ដាយនិងកូន អាចនឹងមានថ្ងៃកំណើតតែមួយ ជាមួយគ្នាបានយ៉ាងដូចម្ដេចទៅ? វាហាក់ដូចជាចៃដន្យពេកហើយ!? នេះអាចជាប្រស្នា ឬជាធម្មៈអ្វីមួយ ដែលអ្នកម៉ាក់ដាក់ឲ្យខ្ញុំ ប្រើបញ្ញាគិតក៏មិនដឹង?...»*

***

បានពីរឆ្នាំមកហើយ ដែល**ខេមរិន្ទ**ធ្វើការ ក្នុងក្រុមហ៊ុនតែមួយជាមួយម្ដាយ។

«**ខេមា**! អង្កាល់ទើបបានកូនប្រសានឹងគេ?» លោកនាយកក្រុមហ៊ុន ដើរកាត់មុខតុទទួលព័ត៌មាន ហើយនិយាយលេង ដោយញញឹមស្រស់ជាមួយ**ខេមា**។

«មិនយូរទៀតទេ ឆាប់ៗនេះហើយ!» **ខេមា**តបទៅអ្នកគ្រប់គ្រងវិញ ថែមទាំងដៀងភ្នែកមើល ក្រមុំរូបស្រស់ម្នាក់ ដែលនៅអង្គុយក្បែរនាង។ លោកប្រធាននិយាយ ចាក់បណ្ដោយតាមៈ

«អូ៎!... បែបនៅជិតៗនេះទេមើលទៅ? សុំឲ្យតែឆាប់ៗណ៎ា ព្រោះបងកំពុងឃ្លានក្បាលជ្រូក!» និយាយហើយអ្នកទាំងបី នាំគ្នាសើច ហាស! ហាស! រួចលោកនាយក ក៏ដើរសំដៅទៅការិយាល័យ ដោយពាំនាំយកទាំងចុងសំណើចទៅផង។

«**មាណវី**! បងសួរបន្តិច... ប្អូនមានសង្សារហើយឬនៅ?» **ខេមា**សួរ**មាណវី** បុគ្គលិកទំនាក់ទំនងថ្មី ដែលទើបតែចូលមកធ្វើការ ដោយមាន**ខេមា**ជាគ្រូជួយបង្ហាត់បង្ហាញ។

«ចាស! នៅទេបង...» **មាណវី**ថ្ពាល់ក្រហម ញញឹមតបដោយអៀនប្រៀន។

«ពិតឬ?... មនុស្សទាំងស្អាត ទាំងពូកែបែបនេះ ឲ្យជឿយ៉ាងម៉េចថា មិនទាន់មានសង្សារ? ឬក៏មានគេមកសួរនាំច្រើនដែរ តែមិនចាប់អារម្មណ៍នឹងគេ?» **ខេមា**ដេញដោលសួរ។

«ចាស! ក៏មានខ្លះៗដែរ តែខ្ញុំមិនចាប់អារម្មណ៍។»

«បើអ៊ីចឹង! ប្អូនស្រឡាញ់មនុស្សបែបណា?» **ខេមា**សួរត។

«ចាស!... គឺ... មុខមាត់ល្មមនឹងមើលបាន ស្មោះត្រង់ជាមួយនឹងយើង ចូលចុះជាមួយអ្នកដទៃបានងាយ ស្រឡាញ់និងចេះឈឺឆ្អាលនឹងយើង រួមទាំងមនុស្សដែលយើងស្រឡាញ់ គឺប៉ាម៉ាក់និងបងប្អូនរបស់យើង តែមិនត្រូវមានចិត្តច្រើនទេ។ ត្រឹមតែប៉ុណ្ណេះ គឺបានហើយសម្រាប់ខ្ញុំ។» ឆោមស្រស់តបយ៉ាងច្បាស់ ហើយម៉ឺងម៉ាត់ ដូចបានគិតត្រៀមទុកជាមុន។ **ខេមា**ស្ដាប់ហើយសើចតិចៗ ហើយសួរបន្តថាៈ

«ត្រូវតែជាអ្នកមានទេ?»

«មិនចាំបាច់សោះ! ទីមួយក៏ខ្លាចចូលជាមួយ សង្គមគ្រួសារគេមិនបាន ព្រោះយើងក៏មិនដឹងថា សង្គមអ្នកមាន គេយ៉ាងម៉េចខ្លះនោះទេ។» ស្រីតូចតបដោយរស្មីភ្នែកស្រទន់ ហើយធ្វើជាសួរលេងទៅវិញថាៈ

«បងសួរខ្ញុំបែបនេះ បែបចង់ណែនាំនរណា ឲ្យខ្ញុំស្គាល់ហើយ មែនទេ?»

«គឺ... អឺ... អត់ទេ! ដឹងទេ? ថ្ងៃកំណើតរបស់ប្អូន គឺត្រូវថ្ងៃតែមួយ ជាមួយបងតែម្តង!» **ខេមា**ប្រញាប់ដូររឿងនិយាយភ្លាមៗ។

«មែនឬបង?» **មាណវី**សួរដោយភ្ញាក់ផ្អើល បង្ហាញស្នេហ៍មុខយ៉ាងស្រស់។

«ជាការពិត!» **ខេមា**អះអាង ហើយនិយាយបន្ត «កូនប្រុសបង ក៏កើតក្នុងថ្ងៃ១០ធ្នូដូចគ្នា ហើយគេក៏ធ្វើការនៅទីនេះដែរ។ បន្តិចទៀត ពេលចេញពីធ្វើការ បងនឹងណែនាំឲ្យស្គាល់។» ទាំងពីរនាក់សើចញញឹមដាក់គ្នា ហើយក៏ធ្វើការងារបន្តទៅ។ **មាណវី**ឈ្ងោកមុខធ្វើការ តែអារម្មណ៍របស់នាងកំពុងតែហោះហើរ... ហោះហើរទៅរកភាពអាថ៌កំបាំងមួយ ដែល**ខេមា**ទើបតែប្រាប់មុននេះ។ មិនមែនជារឿងចៃដន្យពេកឬ មនុស្សបីនាក់ផ្សេងគ្នា មានថ្ងៃកំណើត ចំថ្ងៃតែមួយដូចគ្នា?

នេះហើយគឺ**ខេមា**! នាងធ្វើឲ្យគ្រប់គ្នា ដែលធ្វើការជាមួយ ចូលចុះនឹងនាងយ៉ាងរហ័សព្រមជាមួយនឹងការបង្ហាត់បង្រៀនឲ្យចេះធ្វើការងារ ឆាប់យល់ និងងាយប្រតិបត្តិបានទៀត។ អ្វីដែលគ្រប់គ្នា មិនអាចនឹងមើលរំលងបាននោះ ពេលនេះគេនឹងឃើញច្បាស់ហើយថា **ខេមា**ជាបុគ្គលិកទំនាក់ទំនង ពូកែកម្រិតណា?

ដោយសមត្ថភាពផ្ទាល់ខ្លួន ទេពកោសល្យ ការយកចិត្តទុកដាក់ និងការខិតខំណែនាំបង្រៀនរបស់**ខេមា**, **មាណវី**បានក្លាយជា បុគ្គលិកទំនាក់ទំនងម្នាក់ថ្មីទៀត ដែលធ្វើការបានល្អ ជាទីស្រឡាញ់ចូលចិត្ត និងបានទទួលការជឿជាក់ខ្ពស់ ពីសំណាក់អ្នកគ្រប់គ្រង ក្នុងរយៈពេលយ៉ាងខ្លី។ គុណសម្បត្តិទាំងនេះ បូកផ្សំជាមួយរូបសម្រស់ល្អផូរផង់ សម្តីវាចាពិរោះ និងកិរិយាសុភាពទន់ភ្លន់របស់នាង, **មាណវី**ហាក់ដូចជារស្មីជីវិត របស់ប្រុសកំលោះៗ នៅក្នុងក្រុមហ៊ុន។

មួយឆ្នាំបានកន្លងផុតទៅ... កំលោះៗទាំងឡាយ ដែលមកតាមទាក់ទង**មាណវី** ក៏ចាប់ផ្តើមដឹងខ្លួនថា អស់សង្ឃឹម នៅពេលឃើញ**ខេមរិទ្ធ** និង**មាណវី**បណ្តើរគ្នា ទៅចូលរួមពិធីមង្គលការរបស់បុគ្គលិកនៅក្នុងក្រុមហ៊ុនជាមួយគ្នា។ នៅក្នុងម៉ោងធ្វើការ **មាណវី**ក៏ចូលចិត្តហៅខេមាថា «ម៉ាក់ៗ» ចំណែក**ខេមា**ក៏ហៅ**មាណវី**យ៉ាងពេញៗមាត់ថា «កូន»ដែរ។

«**ខេមរិទ្ធ**នេះ មានម្តាយល្អមែន!» បុគ្គលិកម្នាក់ និយាយនៅក្នុង ពិធីមង្គលការ។

«ឯងទើបតែដឹង!?... បើគ្មានម្តាយគេជួយ ស្មានថា**ខេមរិទ្ធ**ហ្នឹង អាចដៃងពួកយើងបាន? ហ៊ឺយ! នឹកដល់រឿងនេះ គួរឲ្យច្រណែនគេណាស់។» បុគ្គលិកម្នាក់ទៀត និយាយត។

***

«បង**ខេមា**! សុំទោសណា៎... បងធ្វើដូចម្ដេច ទើបប្រើពេលតែមួយឆ្នាំ ក៏យកបវរកញ្ញាលំដាប់ពីរបន្ទាប់ពីបង មកធ្វើជាកូនប្រសាបាន?» **ករុណា**អនុប្រធានគ្រប់គ្រងផ្នែកទីផ្សារ របស់ក្រុមហ៊ុន ដើរមកតុទំនាក់ទំនង ហើយនិយាយលេងសើចជាមួយ**ខេមា**។

«មានបានធ្វើយ៉ាងម៉េច ក្មេងៗស្រឡាញ់គ្នា ជារឿងរបស់ពួកគេ បងចាស់ហើយ ឲ្យបងទៅរើរលំជាមួយម្ដេចនឹងកើត!?» **ខេមា**តប។

«មិនជឿទេ... កូនប្រុសបងឯង មិនមែនជាមនុស្សពូកែទាក់ទងឯណា បើប្រៀបធៀបជាមួយកំលោះៗដទៃទៀត ដែលមកតាមទាក់ទង**មាណវី**? ស្ទើរតែគ្មានផ្លូវទេ ដែលកូនបងឯងអាចទាក់ទងនាងបាន បើមិនមែនជាស្នាដៃរបស់ អ្នកទំនាក់ទំនងដ៏ពូកែ ដែលនៅជាមួយនាងតាំងពីម៉ោង៨ព្រឹក រហូតដល់ម៉ោង៥ល្ងាចដូចរូបបងនោះ។» **ករុណា**និយាយញ៉ោះ**ខេមា**។

«បងគ្រាន់តែណែនាំឲ្យគេស្គាល់គ្នាធម្មតាៗទេ នេះមកពីកូនប្រុសបងមានស្នេហ៍មុខ ដូចម្ដាយគេនោះអី(សើច)... ចុះ**ណា**ថ្ងៃនេះ គ្មានការងារធ្វើទេយ៉ាងម៉េច បានជាមកធាតៅបងទាំងព្រឹកយ៉ាងនេះ?

«ក៏មកមានការនោះអី! គឺ... គឺថា... យើងជាបងប្អូននឹងគ្នា មកជិត១០ឆ្នាំហើយ ចំណែកខ្ញុំឯនេះ អាយុជ្រេជិតដល់៤០ហើយ បងមិនគិតណែនាំនរណាឲ្យខ្ញុំផងទេអី?» **ករុណា**ធ្វើញឹមៗស្នើឲ្យ**ខេមា**ជួយរកគូឲ្យ។ **ខេមា**ឈ្ងក់សំណើច លាន់សួរឃឺះៗតបទៅវិញថា៖

«ឱ! ប្អូនខ្ញុំអើយ... រឿងច្រើនតែខ្លួនឯងហ្នឹង! ត្រូវរ៉ូវនឹងពីណាក៏មិនបានយូរ មិនដឹងថានឹងណែនាំពីណាឲ្យស្គាល់ទៀតទេ! មើលតែម្នាក់ចុងក្រោយនេះដឹងហើយ ត្រូវរ៉ូវគ្នាមិនទាន់ដល់បីខែផង ក៏បែកផ្លូវគ្នាដើរម្នាងម្នាក់ទៅហើយ។ បងមិនដឹងថា នឹងទៅរកនរណា នៅទីណាទៀតទេ បើបានតែបន្តិចក៏ទាស់ទែងគ្នាយ៉ាងនេះ។ បងឯណេះក៏ត្រូវមកជាប់កម្មជាប់ពៀរទៀត ងាកទៅខាងស្រីក៏ខុស ងាកមកខាងប្រុសក៏មិនត្រូវ ហ៊ើយ! ពិបាកមែន...។»

«បងអើយ! មនុស្សពីរនាក់ បើចូលគ្នាមិនបាន ទោះល្អប៉ុណ្ណា ក៏នៅជាមួយគ្នាមិនកើតដែរ។» **ករុណា**តប។

«ឃើញទេ, ដូចប្អូនថាអ៊ីចឹង បើនៅជាមួយគ្នាមិនបាន ក៏ជារឿងរបស់មនុស្សពីរនាក់ ឬបើនៅជាមួយគ្នាកើត ក៏ជារឿងរបស់គេទាំងពីរ។ ចំពោះមនុស្សទី៣ ដែលដើរតួជាមេអណ្ដើក ឬមេកន្ទាយ ទោះជានរណាក៏ដោយ ក៏មិនសំខាន់ដែរ ព្រោះរឿងស្នេហាជារឿងរបស់បេះដូងពីរ ល្អអាក្រក់យ៉ាងណា គឺអាស្រ័យលើគេទាំងពីរហើយ។ ល្អហើយដែលប្អូនមកនិយាយរឿងនេះ ចំថ្ងៃដែល**ខេមរិន្ទ** ចេញទៅធ្វើការនៅខាងក្រៅ។ បើមិនអ៊ីចឹង បែបត្រូវម៉ាស្សាចេញម្ដងហើយ!!!»

***ខេមា***និយាយហើយ ញាក់ភ្នែកញញឹមដាក់***ករុណា***។ ***ករុណា***អង្គុយដកដង្ហើមធំមួយសន្ទុះ ទើបនិយាយថា៖

«អ៊ីចឹងមែនហ្ន៎!...» ថារួច គេក៏ដើរធ្វើល្មើយៗ ចូលក្នុងការិយាល័យ។ ***ខេមា***បានត្រឹមតែញញឹមគ្រវីក្បាលពីក្រោយ។

សម្រាប់***ខេមរិទ្ធ***, ***មាណវី***ជានារីដែលស្អាតទាំងព្រមៗ គ្រប់ពេលដែលឃើញមុខនាង កំលោះទទួលអារម្មណ៍ថា ស្រស់ថ្លារីករាយ តែនៅពេលបាត់មុខនាង ខ្លួនគេក៏ចាប់ផ្តើមរសេះរសោះ ហាក់គ្មានអារម្មណ៍នៅក្នុងខ្លួន។ គ្រប់ពេលដែលបាននៅជិតៗនាង គ្មានអ្វីដែល***ខេមរិទ្ធ***គិតមិនចេញទេ លើកលែងតែរឿង ដែលត្រូវនិយាយជាមួយនាង។ បញ្ហាតែមួយដែលរំខានចិត្ត***ខេមរិទ្ធ*** នៅពេលដែលគេគិតដល់***មាណវី*** គឺ «ជារឿងពិតឬដែលគេនាំគ្នាថា ***ខេមរិទ្ធ***បាន***មាណវី***ជាសង្សារ ព្រោះមានម្តាយជួយចាត់ការឲ្យគ្រប់យ៉ាង ហើយការដែល***មាណវី***មកទាក់ទងនឹង***ខេមរិទ្ធ***នេះ ក៏ព្រោះនាងខ្លាចចិត្ត***ខេមា***ប៉ុណ្ណោះ។»

ថ្ងៃនេះនរៈសង្ហារ បានប្រមូលអស់នូវ សេចក្តីក្លាហានដែលមាន សរសេរក្រដាសតូចមួយដាក់នៅក្នុងថង់អាវរបស់គេថា «***មាណវី***! ខ្ញុំបានឮគ្រប់ៗគ្នានិយាយថា ការដែល***វី***មកធ្វើល្អជាមួយខ្ញុំ ក៏ព្រោះតែ***វី***ខ្លាចចិត្តម៉ាក់ខ្ញុំប៉ុណ្ណោះ មែនទេ?»។

លុះពេលចេញពីធ្វើការ ***ខេមរិទ្ធ***ដើរចេញពីការិយាល័យព្រមគ្នាជាមួយម្តាយ រួមនឹង***មាណវី***ផង។ កំលោះគិតនៅក្នុងចិត្តថា គេនឹងប្រាប់ម្តាយ ឲ្យ***មាណវី***ជួយទៅរើសទិញខោអាវឲ្យ ហើយឲ្យម្តាយគេអញ្ជើញទៅផ្ទះមុន។ ប៉ុន្តែមិនទាន់បាននិយាយអ្វីផង ***មាណវី***ឃើញក្រដាសនៅក្នុងថង់អាវរបស់ខេមរិទ្ធ ទើបនិយាយលេងនឹងកំលោះថា៖

«ក្រដាសអីនេះ បង***រិទ្ធ***?»

***ខេមរិទ្ធ***ភ្ញាក់ព្រើត បែកញើសជោគថ្ងាស ព្រោះខ្លាច***មាណវី***ដឹង។ គេតបដោយសំឡេងញ័រៗថា៖

«ទេ!...គ្មាន... អីទេ...»

***មាណវី***កាន់តែសង្ស័យឡើង ក៏ដណ្តើមយកក្រដាស ពីក្នុងថង់អាវនោះមក៖

«នេះជាលេខទូរស័ព្ទ របស់ស្រីស្នេហ៍មែនទេ?» ***មាណវី***និយាយឡកឡឺ រួចក៏បើកក្រដាសនោះមើល។ ***ខេមរិទ្ធ***ឈរនឹងថ្កល់ បែកញើសជោគខ្លួន ដៃញ័រទទ្រើក មិនដឹងគួរធ្វើយ៉ាងណា។ ចំណែក***ខេមា***ដើរហួសទៅមុខ មុនបន្តិចទៅហើយ។

«បង**រិន្ទ**!?... បងគិតបែបនេះ មែនទេ?» **មាណវី**សួរឡើង នៅពេលបានអានសេចក្ដីក្នុងក្រដាសចប់។ កែវភ្នែកនាងសម្លឹងចំភ្នែក**ខេមរិន្ទ**ឥតព្រិច។ នាយកំលោះស្ងាត់ស្ងៀមមួយស្របក់ ក៏តបទាំងរដាក់រដុបថា៖

«សុំទោស**វី**!... ឲ្យខ្ញុំសុំទោស... ខ្ញុំ...»

«ហ៊ឺះ!... ហ៊ឺះ!!!...» **មាណវី**សើចស្រស់ ទាំងសម្លឹងមកមើល**ខេមរិន្ទ** «ខ្ញុំបានគិតមកហើយថា ត្រូវតែមានរឿងនៅក្នុងចិត្តបងមិនខាន...»

**ខេមរិន្ទ**នឹកប្លែកចិត្ត តែក៏នឹកអរឡើងវិញដែរ ពេលឃើញ**មាណវី**សើច។ ខ្សែភ្នែកគេបញ្ជាក់ប្រាប់ស្រីថា គេនៅមិនទាន់យល់នៅឡើយ។ **មាណវី**ទើបនិយាយត៖

«បង**រិន្ទ**! បងដឹងទេថា ខ្ញុំសំណាងណាស់ ដែលបានមកធ្វើការ នៅក្នុងក្រុមហ៊ុននេះ។ សំណាងដែលបានម៉ាក់បង ជាអ្នកបង្ហាត់បង្ហាញ។ សំណាងដែលម៉ាក់ ណែនាំខ្ញុំឲ្យស្គាល់បង ហើយសំណាង ដែលបងប្រាប់ថា ស្រឡាញ់ខ្ញុំ។ ខ្ញុំមានចរិតមួយ ដែលមិនទាន់ប្រាប់បង ហើយបងក៏នៅពុំទាន់ដឹង... នោះគឺ ខ្ញុំជាមនុស្សដែលមិនចូលចិត្ត ដើរយកចិត្តអ្នកដទៃ។ បើខ្ញុំមិនចង់រាប់អានជាមួយអ្នកណា ខ្ញុំក៏មិនចាំបាច់ធ្វើល្អជាមួយអ្នកនោះដែរ។ ហើយខ្ញុំក៏មិនចូលចិត្តធ្វើល្អលើមនុស្សម្នាក់ ដើម្បីផ្គាប់ចិត្តមនុស្សម្នាក់ទៀតនោះឡើយ។ ចង់ដឹងទេថា?... ហេតុអី ខ្ញុំមកចាប់ចិត្តស្រឡាញ់បង? គឺមិនមែនមកពីបង មានភ្នែកមុតសម្លឹផ្អែម ពូកែនិយាយលួងលោម មុខមាត់ស្រស់សង្ហា ឬព្រោះបងមានរថយន្តជិះនោះទេ។ តែព្រោះបងជាកូនរបស់ម៉ាក់ ទើបធ្វើឲ្យបងមានគុណធម៌ និងមន្តស្នេហ៍ ដែលកប់ជ្រៅ ដូចម៉ាក់បងដែរ។ មិនមែនព្រោះខ្ញុំ ត្រូវធ្វើល្អជាមួយម៉ាក់បងទេ តែព្រោះសេចក្ដីស្នេហ៍ ភាពគួរឲ្យស្រឡាញ់ ភាពកក់ក្ដៅរបស់បងនិងគ្រួសារ។ មនុស្សយើងតែងចង់រស់នៅ ជាមួយមនុស្សដែលនៅក្បែរគ្នាហើយ បានសប្បាយចិត្ត អាចនិយាយគ្នាបានដោយស្មោះត្រង់អស់ពីចិត្ត ហើយជាមនុស្សដែលចង់មើលថែរក្សាខ្លួនដោយពិតៗ។ សម្រាប់ខ្ញុំ បងគឺជាម្នាក់នោះហើយ។ ម្យ៉ាងទៀត ខ្ញុំក៏មិនចាំបាច់ភ័យខ្លាចថា បងនឹងមានអ្នកថ្មីចាកចោលខ្ញុំដែរ ព្រោះថ្វីបើមុខបងមានស្នេហ៍មែន តែបងមិនសូវចេះទាក់ទងស្រីៗ ឬពូកែយកចិត្តគេដូចអ្នកម៉ាក់នោះទេ។» **មាណវី**សើចតិចៗ ហើយនិយាយត «ទៅ! ត្រឡប់ទៅផ្ទះ ម៉ាក់បងកំពុងឈរចាំឯណោះ!»។

តាំងពីថ្ងៃនោះមក **ខេមរិន្ទ**កាន់តែស្រឡាញ់**មាណវី**ទ្វេឡើង។ គេប្ដេជ្ញាចិត្តថា មុនអាយុ២៥ ឆ្នាំ គេនឹងឲ្យម្ដាយ ទៅចូលស្ដីដណ្ដឹងនាងឲ្យបាន។ នាយប្រឹងប្រែងធ្វើការងារ និងសន្សំប្រាក់យ៉ាងអស់ពីសមត្ថភាព។ ក្រៅពីធ្វើការនៅក្រុមហ៊ុន គេនៅធ្វើការក្រៅបន្ថែមទៀត។ គេធ្វើជាអ្នក

រត់ការឯកសារផង ធ្វើជាឈ្មួញកណ្ដាលលក់ផ្ទះឬដីផង និងធ្វើការងារផ្សេងៗទៀតគ្រប់កន្លែងដែលមានមនុស្សឲ្យធ្វើ ហើយដែលគេជឿជាក់ថា ខ្លួនឯងអាចធ្វើបាន។ ពេលគេកំពុងធ្វើការចរន្តគំនិតរបស់គេ តែងនឹកទៅដល់សម្ដី របស់មិត្តសម្លាញ់គេម្នាក់ ដែលបានប្រាប់គេថា «បើចង់បានកូនស្រីទោល របស់ស្នងការប៉ូលីសចូលនិវត្តន៍ ដូច**មាណវី**នេះ ឯងត្រូវត្រៀមទាំងឋានៈគ្រួសារនិងលុយកាក់ឲ្យបានច្រើន ដើម្បីឲ្យស័ក្តិសមនឹងមុខមាត់របស់គេ។ គ្នាគិតថាលុយបណ្ដាប់ការរបស់**មាណវី** មិនទាបជាង២០០០ដុល្លាទេ!»។ សម្ដីនេះបានធ្វើឲ្យ**ខេមរិទ្ធ** ត្រូវខំធ្វើការខាងក្រៅបន្ថែមច្រើនឡើងៗ។

***

«ឥឡូវនេះ បង**រិទ្ធ**នៅផ្ទះមិនសូវជាប់សោះ ម៉ាក់!?» **មាណវី**នឹកឆ្ងល់ជាមួយនឹង**ខេមា**នៅព្រឹកថ្ងៃសៅរ៍មួយ ខណៈដែលគេទាំងពីរ កំពុងទៅសួរសុខទុក្ខលោក**ប្រសិទ្ធិ** ឪពុករបស់**មាណវី**នៅមន្ទីរពេទ្យ។

«កូន**រិទ្ធ**ជាមនុស្សម៉ត់ចត់ក្នុងការងារ ហើយនៅក្មេងកម្លាំងមាំ ទើបលោកប្រធានទុកចិត្តក៏បញ្ជូនគេ ឲ្យទៅទាក់ទងការងារខាងក្រៅ ជាមួយអតិថិជនថ្មីបន្ថែមមួយព្រឹកនេះទៀត។» **ខេមា**តប**មាណវី**។

«កូនយល់! តែអ្នកដទៃទៀត ក៏គេនៅធ្វើបានឲ្យគគោក គាត់បែរជាចូលចិត្តស្ម័គ្រខ្លួនទៅមុនគេរហូត។ ធ្វើការច្រើនអត់ឈប់សម្រាកបែបនេះ មិនដឹងជាគាត់ចង់បានលុយ យកទៅធ្វើអីហ្ន៎... ម៉ាក់!?» **មាណវី**អ៊ូតិចៗ។

«កូនអត់ដឹងទេ?... គេធ្លាប់ប្រាប់ម៉ាក់ថា គេនឹងខំធ្វើការសន្សំប្រាក់ ទុករៀបការជាមួយកូននោះអី!»

«នរណាប្រាប់គាត់ថា ខ្ញុំចង់រៀបការជាមួយគាត់!?» ធីតាសោភាក្រហមមុខ និយាយដោយអៀនប្រៀន។ **ខេមា**ដឹងថានាងអៀន ក៏ប្រញាប់ដូររឿងនិយាយ៖

«តោះ! លឿនឡើង ប៉ាកូនបែបចាំយើងហើយ!»

អ្នកទាំងពីរប្រញាប់បង្កើនចង្វាក់ជើងដើរ។ មកដល់មន្ទីរពេទ្យ ពួកគេក៏ដើរសំដៅបន្ទប់ដែលលោក**ប្រសិទ្ធិ**ដេកសម្រាកព្យាបាល។ ចៃដន្យ**មាណវី**ក្រឡេកឃើញមិត្តចាស់ម្នាក់ ដែលធ្លាប់រៀនជាមួយគ្នា កំពុងអង្គុយលើរទេះរុញ នាងក៏ដើរសំដៅទៅគេ ដោយប្រាប់ទៅ**ខេមា**ថា៖

«ម៉ាក់ទៅមើលប៉ាមុនចុះ! ខ្ញុំទៅជួបមិត្តចាស់មួយភ្លែតៗ បន្តិចទៀត ខ្ញុំនឹងទៅតាមក្រោយៗ» **ខេមា**ញញឹមតប ហើយដើរទៅរក បន្ទប់អ្នកជម្ងឺម្នាក់ឯងៗ

«ជម្រាបសួរលោកបង!» លោក**ប្រសិទ្ធិ** ដែលកំពុងដេកផ្អែកនឹងក្បាលគ្រែ អានកាសែត ពេលក្រឡេកឃើញ**ខេមា**ចូលមក ក៏ទុកកាសែតចុះហើយញញឹមតបមកវិញ៖

«ជម្រាបសួរអ្នក! យ៉ាងម៉េចហើយ... ចុះឯណាកូនស្រីខ្ញុំ និងកូនប្រុសអ្នក?»

«កូនស្រីលោកបង ជាប់និយាយជាមួយមិត្ត នៅខាងក្រៅៗ ឯកូនប្រុសខ្ញុំ ជាប់រវល់ការងារបន្តិចបន្តួច មិនបានមកទេៗ» **ខេមា**តបៗ

«អូ្ហ! ក្រែងថ្ងៃនេះជាថ្ងៃសៅរ៍ មិនមែនឬ? ចុះគេមិនបានសម្រាកទេឬអី?» ប៉ារបស់**មាណវី** សួរតៗ

«តាមធម្មតាក៏បានសម្រាក តែថ្ងៃនេះលោកប្រធាន បបួលទៅជួបអតិថិជនថ្មី ទើបខកខានមិនបានមកៗ»

«អូ៎! ល្អៗ... ក្មេងៗសប្បាយនឹងធ្វើការងារបែបនេះ ជាការប្រសើរខ្លាំងណាស់ៗ បើយ៉ាងនេះមិនយូរទេ នឹងឆាប់មានឆាប់បានហើយៗ» អតីតស្នងការប៉ូលីសសរសើរៗ **ខេមា**ញញឹមបន្តិចក៏តបទៅវិញ៖

«នៅយូរទៀតណាស់លោកបង រឿងមានរឿងបាននោះ! និយាយអ៊ីចឹង បងស្រីគាត់អញ្ជើញទៅណា បានជាមិនឃើញមក?»

«អូ៎! ថ្ងៃនេះកូនប្រុសនិងកូនប្រសាទៅការគេ ហើយក៏បានយកក្មេងមកផ្ញើនឹងយាយវាៗ ខ្ញុំបានប្រាប់គេឲ្យយកមកមន្ទីរពេទ្យដែរ តែគេប្រាប់ថា ក្មេងវាធុំថ្នាំ ហើយរពឹសណាស់ ខ្លាចរំខានខ្ញុំ ទើបគេមិនមក ក៏នៅចាំមើលចៅៗឯផ្ទះទៅៗ ចុះអ្នកវិញ មិនគិតចង់បានចៅបានអី នឹងគេខ្លះទេឬ? ក្មេងៗក៏ស្គាល់គ្នា បានជាងមួយឆ្នាំហើយដែរៗ ចាំអង្គាល់ទៀត បានចូលមកសួរនាំ?»

«ចាស! កំពុងសន្សំលុយកាក់ ទុកថានឹងចូលស្ដីហើយៗ ឯកូនប្រុសខ្ញុំ ក៏ចេះតែចង់ចូលមកឆាប់ៗដែរ តែខ្លាចឋានៈខាងខ្ញុំមិនសមនឹងលោកបង ទើបគេខិតខំធ្វើការ មិនមានថ្ងៃសៅរ៍ថ្ងៃអាទិត្យដូច្នេះៗ កូន**រិទ្ធ**ថា ទោះយ៉ាងណាក៏ត្រូវសាងឋានៈគ្រួសារ ឲ្យស័ក្ដិសមនឹងលោកបងសិនដែរៗ» ឪពុករបស់**មាណវី**ញញឹម ហើយនិយាយ៖

«ផ្ទះខ្ញុំគ្រាន់តែជាផ្ទះស្នងការចូលនិវត្តន៍តូចតាចធម្មតាប៉ុណ្ណោះ មិនមែនអ្នកធំមានមុខមាត់មកពីណានោះទេៗ អារឿងមុខរឿងមាត់នេះ ខ្ញុំមិនខ្វល់ទេ, ពិធីមង្គលការតូចឬធំមិនសំខាន់ឡើយ តែអ្វីដែលត្រូវគិតនោះ គឺសមត្ថភាពរបស់គេទៅវិញតើ! ចំពោះប្រាក់បណ្ដាប់ថ្លៃទឹកដោះទឹក

អីនេះ ខ្ញុំមិនយកទេ ខ្ញុំត្រូវការតែកូនប្រសាដែលមានសមត្ថភាព ហើយចេះគោរពស្រឡាញ់ និង ចេះមើលថែរក្សាកូនស្រីរបស់ខ្ញុំបានរហូតទៅ ក៏គ្រប់គ្រាន់ណាស់ទៅហើយ។»

ស្ងៀមមួយស្របក់ លោក**ប្រសិទ្ធិ**បន្ទូរដង្ហើមបន្តិច ក៏និយាយតះ

«ខ្លួនខ្ញុំកាន់តែចាស់ទៅហើយ មិនដឹងថាបាននៅឃើញកូនយូរប៉ុណ្ណាទៀតទេ។ តែយ៉ាង ណាក៏ចង់ឃើញកូនមានគ្រួសារដែលល្អ និងមានអ្នកមើលថែសិនដែរ។»

«ម៉េចក៏លោកបងនិយាយដូច្នេះ ខ្ញុំឃើញលោកបងនៅរឹងមាំល្អណាស់។»

ឪពុក**មាណវី**សើចតិចៗ ហើយនិយាយតបះ

«ប៉ុណ្ណោះ បងគ្មានទៅមាំទាំអីទេ។ បើគិតដល់ពីមុន មិនថាតែគ្រាប់បែក គ្រាប់កាំភ្លើងក៏ ធ្លងកាត់មកអស់ដែរ ។ត្រូវគ្រាប់ត្រូវផ្ទោង ឈាមដាបខ្លួន ក៏នៅរត់បានជម្មតា។ តែឥឡូវនេះ មូស ខាំបឺតឈាមអស់តែបន្តិច ក៏ក្លាយជាគ្រុនជាឈឺ រហូតត្រូវមកដេកពេទ្យទៀត។»

អ្នកទាំងពីរនិយាយគ្នាបន្តទៅទៀតបានបន្តិច **មាណវី**ក៏ចូលមក។ ថ្ងៃនេះអ្នកទាំងបី និយាយគ្នាពីនេះពីនោះច្រើនរឿងណាស់ រួមទាំងរឿងរៀបចំពិធីបុណ្យខួបកំណើត នៅក្នុងរយៈ ពេលពីរអាទិត្យខាងមុខទៀត។

***

ថ្ងៃសុក្រ ថ្ងៃទី០៨ធ្នូ ខណៈដែលកំពុងរៀបនឹងចេញពីធ្វើការពេលព្រឹក **ករុណា**ដើរមក រកខេមរិន្ទដល់តុធ្វើការ ដើម្បីបបួល**ខេមរិន្ទ**ទៅជួបអតិថិជន នៅខេត្តសៀមរាបជាមួយគ្នា។ **ករុណា**នឹងប្រគល់តំណែងអនុប្រធានគ្រប់គ្រងផ្នែកទីផ្សារ និងភាគរយប្រាក់ចំណេញយ៉ាងច្រើន ដល់ខេមរិន្ទ បើកាលណាគេធ្វើការងារនេះបានសម្រេច។

នៅពេលស្រស់ស្រូបអាហារថ្ងៃត្រង់ **ខេមរិន្ទ**ក៏និយាយរឿងនេះប្រាប់ម្តាយ និង**មាណវី**។ ពេលស្តាប់ដឹងរឿង **ខេមា**ក៏សួរះ

«ចុះកូនទៅប៉ុន្មានថ្ងៃ?»

«ក៏មិនទាន់ច្បាស់ដូចគ្នាម៉ាក់! គឺអាស្រ័យលើខាងនោះទេ។»

**មាណវី**បង្អន់ទំពាររបាយបន្តិច ក៏និយាយតទៅ**ខេមរិន្ទ**ះ

«បងត្រូវត្រឡប់មកវិញឲ្យទាន់ថ្ងៃអាទិត្យណ៎ា!»

**ខេមរិន្ទ**លើកទឹកផឹកបន្តិច រួចនិយាយទាំងចិញ្ចើមជ្រួញទ្រង់ធ្ងល់ះ

«ថ្ងៃអាទិត្យឬ? មានរឿងអីមែនទេ?»

«ចាស!... សុំមកឲ្យទាន់ណ៎ា!»

«បងនឹងព្យាយាមៗ»

ក្រោយពីអាហារថ្ងៃត្រង់ហើយ **ខេមរិន្ទ**ក៏ប្រញាប់ត្រឡប់ទៅផ្ទះ រៀបចំខោអាវ និងសំណុំឯកសារមួយចំនួន មុននឹងចូលមកក្រុមហ៊ុនវិញ ហើយបន្តចេញដំណើរៗ

«ប្អូន**ណា** ម៉េចៗកុំនាំកូនបង ក្រវេលណេះក្រវេលណោះណ៎ា!» **ខេមា**និយាយផ្ដាំផ្ញើនឹង **ករុណា** បែបលេងលាយមែនៗ

«កុំព្រួយបង! ទៅជាមួយខ្ញុំហើយ កុំបាច់បារម្ភអី ដេកតែពីក័យទៅ!»

«នៅហ៊ានិយាយលេងទៀត! អត់ដឹងខ្លួនទេ ថាបងបារម្ភព្រោះ ទៅជាមួយប្អូននេះហើយ?!...» **ករុណា**សើចស្រស់ផ្ទាំកមក មុននឹងឡើងឡានចេញទៅៗ

***

ថ្ងៃអាទិត្យ **មាណវី**មកផ្ទះ**ខេមា** តាំងពីព្រឹកព្រលឹម ដោយមានរបស់របរជាច្រើន សម្រាប់ត្រៀមចំអិនអាហារ និងធ្វើនំខួបកំណើតៗ **ខេមា**ចេញមកទទួលរបស់ទាំងនោះពី**មាណវី** ព្រមជាមួយវាចាយ៉ាងទន់ភ្លន់ៈ

«កូន**វី**! កូនដូចជាត្រៀមរបស់ច្រើនដល់ហើយនៀក?»

នរនាថបន្ទឺវាចាញញឹមស្រស់ៈ

«ចាស! កូនថានឹងត្រៀមរបស់ញាំឲ្យបានច្រើន ទុកសម្រាប់មិត្តភក្តិ ទាំងមិត្តនៅក្នុងក្រុមហ៊ុន និងមិត្តចាស់ៗដែលធ្លាប់រៀនជាមួយគ្នា ដែលពួកគេនឹងមកនៅថ្ងៃនេះៗ កូនបានហៅភ្ញៀវមកច្រើនណាស់! ម៉ាក់មិនថាអីទេ?»

**ខេមា**គ្រវីក្បាលញញឹមតបៈ

«កូនឆ្កួត! ម៉ាក់មានទៅថាអីៗ ម៉ាក់ក៏ចូលចិត្តមនុស្សច្រើនដូចគ្នា មិត្តរបស់កូនក៏ដូចជាមិត្តរបស់ម៉ាក់ដែរ ជាពិសេសអ្នកនៅក្រុមហ៊ុនៗ ចុះប៉ានិងម៉ាក់កូននោះ ម៉េចៗថ្ងៃនេះ កុំឲ្យបាត់មុខពួកគាត់ណ៎ា!»

«ចាស!... តែព្រឹកនេះគាត់មិនទាន់អញ្ជើញមកទេៗ គាត់បានប្រាប់ថា ព្រឹកនេះមានណាត់ជាមួយមិត្តភក្តិ ដូច្នេះពួកគាត់ក៏អញ្ជើញទៅតាមណាត់សិន លុះពេលរសៀលទើបពួកគាត់អញ្ជើញមកទីនេះៗ»

**ខេមា**ចាប់លើកថង់ម្សៅ និងស៊ុតទាមើល ហើយឧទានឡើងៈ

«អ្ហ៎!... ម្សៅនិងពងទាមានច្រើនណាស់តើ! កូនប្រុងនឹងធ្វើអីខ្លះទៅ?»

«កូននឹងធ្វើនំខេកបីដុំធំៗ អាធំជាងគេសម្រាប់ម៉ាក់ អាពីរធំបន្ទាប់សម្រាប់បង**រិទ្ធ**និងខ្ញុំ។... និយាយដល់បង**រិទ្ធ** គាត់មានបានទូរស័ព្ទមកម៉ាក់ទេ? យប់មិញនេះ ខ្ញុំទូរស័ព្ទទៅរកគាត់ដែរ តែបែរជាក្រៅតំបន់សេវារហូត។»

**ខេមា**លាយម្សៅបណ្ដើរនិយាយបណ្ដើរ៖

«យប់មិញគេក៏បានទូរស័ព្ទមកម៉ាក់ដែរ គេប្រាប់ថាការងារនឹងបញ្ចប់នៅព្រឹកនេះ ហើយគេនឹងរួសរាន់មកភ្នំពេញវិញតែម្ដង ប្រហែលជាយប់ទើបមកដល់។»

«ចុះគាត់មិនបាននិយាយរឿងខួបកំណើតទេឬម៉ាក់?»

«អត់ទេ! កូន**រិទ្ធ**បែបហត់នឿយនឹងការងារ នៅឯណោះខ្លាំងពេកហើយ ទើបគេភ្លេច។»

«មនុស្សអីឆ្កួតនឹងការងារហួសហេតុ សូម្បីតែថ្ងៃកំណើតខ្លួនឯងក៏ចាំមិនបាន! ចំនែកម៉ាក់ក៏ចិត្តល្អនឹងគាត់ទៀត!»

«ណ្ហើយចុះ! ទោះយ៉ាងណាក៏ទៅធ្វើការទៅធ្វើងារដែរ ប្រសើរជាងគេទៅផ្លូវផ្សេងៗ មកជួយគ្នាត្រៀមរៀបចំអាហារវិញល្អជាង តិចមិនទាន់ល្ងាចនេះទៅ។»

អ្នកទាំងពីរក៏មូលដៃគ្នា រៀបចំចាត់ចែងគ្រឿងប្រដាប់ផ្សេងៗ ទៅតាមតម្រូវការនៅក្នុងឱកាសបុណ្យខួបកំណើតល្ងាចនេះ។

នៅក្នុងពេលជាមួយគ្នានោះ នៅឯខេត្តសៀមរាបឯណោះ **ខេមរិទ្ធ**និង**ករុណា**កំពុងត្រៀមខ្លួនចរចា ជាមួយអតិថិជនជាលើកចុងក្រោយ ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាវិនិយោគ។

«**រិទ្ធ**! ត្រៀមខ្លួនហើយមែនទេថ្ងៃនេះ? កុំភ្លេចបិទទូរស័ព្ទណា! ពូបានឮមកថា លោកនាយកធំខាងគេនោះ មិនចូលចិត្តឲ្យមានសំឡេងអ្វីមករំខាន ក្នុងពេលជជែករឿងការងារទេ។» **ករុណា**ដាស់តឿន**ខេមរិទ្ធ**។ យុវកំលោះលើកទូរស័ព្ទមកបិទ ហើយញញឹមតបទៅវិញ៖

«បាទ លោកពូ!»

«កុំហៅពូថា លោកពូនៅមុខអ្នកដទៃឮទេ? ហៅបាន ពេលនៅតែពីរនាក់ និងពេលនៅចំពោះមុខម៉ាក់ឯងប៉ុណ្ណោះ យល់ទេ!?»

**ខេមរិទ្ធ**សើចស្រស់៖

«យល់ហើយលោកពូ! លោកពូខ្លាចគេថា លោកពូចាស់មែនទេ?»

«នៅហ៊ានមកសួរទៀត! ទៅ!... ទៅធ្វើការយើងត តិចមិនទាន់ម៉ោង!!!»

***ករុណា***ដេញគម្រាមខេមរិន្ទ ពេលនរៈនិយាយត្រូវចំណុចៗ បន្ទាប់មកអ្នកទាំងពីរ ក៏ចូលទៅ ក្នុងសណ្ឋាគារ ដែលជាទីកន្លែងណាត់ជួបចរចាការងារៗ

*ចំណែកនៅខាងផ្ទះឯណោះវិញ* ***ខេមា***និង***មាណវី***បានត្រៀមអ្វីៗគ្រប់បែបយ៉ាង ជិតរួចរាល់ហើយ នៅសល់តែដុតនំខេក និងរចនាលំអលើនំប៉ុណ្ណោះៗ

*«ម៉ាក់ធ្វាក់នំខេករបស់ខ្ញុំចុះ ទុកឲ្យខ្ញុំធ្វាក់នំរបស់ម៉ាក់ និងបង***រិទ្ធ***ៗ»*

***ខេមា****ញញឹម ហុចនំទាំងពីរ ឲ្យទៅ****មាណវី****៖*

*«ក៏បាន...»*

*ពេលទទួលនំ* ***មាណវី****ធ្វើមុខប្លែក ហើយសង្កេតមើលទឹកមុខ****ខេមា*** *ដោយយកចិត្តទុកដាក់៖*

*«ម៉ាក់! ម៉េចក៏ទឹកមុខស្លាំងម្ល៉េះ មិនមែនហត់ពេកឬ? ម៉ាក់ទៅសម្រាកចុះ! ទុកឲ្យកូនធ្វើខ្លួនឯងក៏បានៗ»*

***ខេមា****គ្រវីក្បាលញញឹម៖*

*«ម៉ាក់មិនអីទេ! ក្អែកកូនមើលច្រឡំទេដឹង?...»*

*ភ្លាមនោះស្រាប់តែ មានឈាមហូរចេញ ពីច្រមុះ****ខេមា****យ៉ាងគគាក់ ហើយនាងក៏ដួលព្រួសសន្ធប់ឈឹងៗ មាណវីស្ទុះទៅឱប****ខេមា****ជាប់ មុននឹងនាងរលំដួលទៅលើឥដ្ឋៗ ទោះបីជា****មាណវី****ខំធ្វើចលនាឲ្យនាងយ៉ាងណាក៏ដោយ ក៏****ខេមា****នៅតែបាត់សតិដដែលៗ* ***មាណវី****ក៏យកដៃចាប់យកទូរស័ព្ទហៅទៅឪពុកនាង៖*

*«លោកប៉ា! ប៉ានៅឯណាហ្នឹង?»*

*«អ៊ូ! កូន****វី****ហ្នំ... ប៉ាកូនកំពុងបើកឡាន កូនមានរឿងអី?»*

*សំឡេងពីខ្សែម្ខាង ជាម្ដាយ****មាណវី****ៗ ពេលឮម្ដាយទទួលបានទូរស័ព្ទហើយ នួននាងប្រញាប់និយាយត ដោយសំឡេងញ័រស្អកស្អះ*

*«ម៉ាក់នៅឯណាហ្នឹង? ពេលនេះម៉ាក់បង****រិទ្ធ****មិនដឹងយ៉ាងម៉េចទេ គាត់ដួលបាត់ស្មារតី ហើយថែមទាំងមានឈាមហូរចេញពីច្រមុះ ច្រើនទៀតផង!»*

*ម្ដាយ****មាណវី****បើកភ្នែកស្លី ភ្ញាក់ផ្អើលដោយរន្ធត់ចិត្ត៖*

*«មែនហ៎?... ព្យាយាមធ្វើចលនាគាត់ឲ្យស្រួល ម៉ាក់ទៅជិតដល់ហើយ!» ម៉ាក់****មាណវី****ដាក់ទូរស័ព្ទចុះ ហើយនិយាយដោយស្ងួន ទៅកាន់ស្វាមី «ប៉ាវ៉ាបើកឲ្យលឿនៗទៅ ម៉ាក់កូន****រិទ្ធ****ខ្យល់ដួលសន្ធប់ មិនដឹងថាយ៉ាងម៉េចទៅហើយទេ នៅឯផ្ទះឯណោះ!!!»*

«មានរឿងអ៊ីចឹងផង!!!???» លោក**ប្រសិទ្ធិ**ឧទាន ហើយប្រញាប់បន្ថែមល្បឿនរថយន្តឲ្យកាន់តែលឿនឡើង។

មិនដល់ប្រាំនាទីផង ប៉ារបស់**មាណវី**ក៏បើកឡានមកដល់។ «មិនដល់ប្រាំនាទី» អាចជាពេលដ៏លឿនបំផុត តែសម្រាប់**មាណវី** វាជារយៈពេលរង់ចាំដ៏យូរបំផុត។ ចុះពីលើឡានកាលណា ប៉ាម៉ាក់ស្រស់ស្រី ក៏ប្រញាប់ស្ទុះស្ទារត់មកមើល**ខេមា** ហើយក៏ជួយគ្នាលើកនាងដាក់ឡានបញ្ជូនទៅមន្ទីរពេទ្យ។ **មាណវី** ប្រញាប់បិទភ្លើងបិទទឹក និងរៀបចំបិទបង្អួចទ្វារ មុននឹងចេញទៅមន្ទីរពេទ្យ។

ពេលទៅដល់មន្ទីរពេទ្យ តូចតន់ព្យាយាមចុចទូរស័ព្ទទៅរក**ខេមរិន្ទ** ជាច្រើនលើកច្រើនសារ ប៉ុន្តែបានត្រឹមតែឮសំឡេងឆ្លើយតបដដែលៗមកថា «សូមអភ័យទោស ទូរស័ព្ទដែលលោកអ្នកកំពុងហៅ មិនអាចទាក់ទងបានទេនៅពេលនេះ សូមព្យាយាមម្តងទៀតនៅពេលក្រោយ...»។ បន្ទាប់មក **មាណវី**ក៏ចុចទូរស័ព្ទ ទៅរកបងប្រុសរបស់**ខេមា**វិញ ដែលគាត់ជាសាច់ញាតិតែម្នាក់គត់ដែល**មាណវី**ស្គាល់លេខទូរស័ព្ទ។

នៅពេលបានទទួលដំណឹងភ្លាម បងប្រុសតែមួយរបស់**ខេមា** ដែលរស់នៅក្រុងព្រះសីហនុ បានប្រញាប់ប្រញាល់ទិញសំបុត្រយន្តហោះ ឡើងមកភ្នំពេញជាបន្ទាន់។ លុះមកដល់ភ្នំពេញ គាត់ក៏ទាក់ទងប្រាប់ដំណឹង ដល់សាច់ញាតិបងប្អូន ខាងប៉ារបស់**ខេមរិន្ទ**បន្ថែមទៀត។ ខណៈពេលជាមួយគ្នានោះ មិត្តភក្តិរបស់**មាណវី** ក៏មកដល់ផ្ទះ**ខេមា**អស់ទៅហើយដែរ។ តែពេលមិនឃើញមាននរណានៅផ្ទះ ក្រៅពីទ្វារចាក់សោជាប់ ពួកគេក៏ទូរស័ព្ទទៅសួរ**មាណវី**។ ពេលបានទទួលដំណឹង ពួកគេក៏នាំគ្នាមកមន្ទីរពេទ្យ។ ចំពោះមិត្តភក្តិដែលនៅកន្លែងធ្វើការ ក៏នាំគ្នាទូរស័ព្ទប្រាប់មិត្តភក្តិដទៃទៀត តាំងពីអ្នកគ្រប់គ្រង រហូតដល់សន្តិសុខ។

ម៉ោង៥ល្ងាច មានមនុស្សមកមន្ទីរពេទ្យ យ៉ាងច្រើនកុះករ ដើម្បីមកមើលអាការៈរបស់**ខេមា** និងផ្តល់កម្លាំងចិត្តដល់នាង។ បងប្រុសរបស់**ខេមា** រវល់ទាក់ទងជាមួយមិត្តភក្តិគ្រប់ៗគ្នាដោយកាយវិការនឹងធឹង។ តែទាំងអស់គ្នាក៏សង្កេតឃើញ មានទឹកថ្លាៗដក់ជាប់ក្នុងប្រឡង់ភ្នែករបស់គាត់ដែរ គឺប្រុងតែហូរធ្លាក់មកគ្រប់ពេលទាំងអស់។ សោតឯសំឡេងទៀតក៏ញ័រៗ ស្អកស្អា ពិបាកនឹងស្តាប់បន្តិច តែល្មមនឹងយល់បាន។ មានសំណួរមួយដែលនរណាៗក៏ឆ្ងល់ និងចោទសួរគ្នាទៅវិញទៅមកគឺ ***«ខេមរិន្ទ នៅឯណា?»*** ។ គ្រប់ៗគ្នា មិនថាតែ**មាណវី**ទេ បានព្យាយាមទាក់ទងទៅរកនរៈជាច្រើនលើកច្រើនសារ ប៉ុន្តែនៅតែមិនអាចទំនាក់ទំនងបានដដែល។

ម៉ោង៧យប់ គ្រូពេទ្យបានចេញមកសួររកបងប្អូនជិតស្និទ្ធ របស់**ខេមា**។ ដំបូងបងប្រុសរបស់នាងចូលទៅតែម្នាក់ឯង បន្តិច**មាណាវី**ក៏ចូលទៅជាមួយ។ **ខេមា**ញញឹមពេលឃើញមុខបងប្រុស និង**មាណាវី**។ អ្នកទាំងពីរអង្គុយបន្ទាបខ្លួន នៅក្បែរគ្រែ។ ដៃប្អូនចាប់ដៃខាងឆ្វេងរបស់**ខេមា** , ត្រចៀកប្អូនផ្ទៀងស្តាប់ពាក្យគ្រប់ម៉ាត់របស់នាង៖

«កូន**រិទ្ធ**នៅមិនទាន់មកទេ? បើគេមកសូមកូនយកកាដូថ្ងៃកំណើត នៅលើក្បាលគ្រែរបស់ម៉ាក់ឲ្យគេផង។ កាដូរបស់កូនក៏ទុកនៅក្បែរៗគ្នានោះដែរ ម៉ាក់បានសរសេរឈ្មោះបិទនៅលើនោះស្រាប់ហើយ។ អរគុណដែលបងមក(**ខេមា**បែរភ្នែកទៅរកបងប្រុស បន្ទាប់ពីនិយាយជាមួយ**មាណាវី**ចប់) ថ្ងៃរបស់ប្អូនបានមកដល់ហើយ... បងយល់ហើយមែនទេ?»

សាច់ញាតិតែម្នាក់គត់របស់**ខេមា** ងក់ក្បាលស្រក់ទឹកភ្នែកធ្លាក់លើដៃនាង៖

«បងយល់!... តែបងមិនគិតសោះថា វាលឿនដល់ថ្នាក់នេះ?»

**ខេមា**ញញឹមស្ងួតទាំងទឹកភ្នែក ងាកទៅរក**មាណាវី**៖

«ម៉ាក់សឹងតែភ្លេច... រីករាយថ្ងៃកំណើត... កូន**វី**! ម៉ាក់សុំផ្ញើ... រីករាយថ្ងៃកំណើត... កូន**រិទ្ធ**ផង...»

**ខេមា**បិទភ្នែកសន្សឹមៗ ជាមួយស្នាមញញឹម, បងប្រុសនាងនិង**មាណាវី**រំជួលចិត្ត ស្រក់ទឹកភ្នែកប្រោកៗ ដូចភ្លៀងធ្លាក់។ ឪពុកមាររបស់**ខេមរិទ្ធ**ខំលេបទឹកមាត់ បំបាត់អាការស្ទះអួលក្នុងបំពង់ក ហើយពោលពាក្យជូនពរប្អូនស្រី ចេញពីជម្រៅចិត្តយ៉ាងអួលអាក់៖

«រីករាយថ្ងៃខួបកំណើត... **ខេមា**!»

**មាណាវី**ក្តោបដៃ**ខេមា**យ៉ាងណែន ហើយពោលពាក្យជូនពរទាំងខ្សឹកខ្សួល៖

«រីករាយថ្ងៃកំណើតម៉ាក់!...»

នេះអាចជាពាក្យចុងក្រោយ ដែល**ខេមា**បានឮ មុននឹងដៃរបស់នាងរបូតចេញ ពីដៃរបស់បងប្រុសនិង**មាណាវី**។ បងប្រុស**ខេមា**ដឹងច្បាស់ណាស់ ថានាងគ្មានផ្លូវនឹងរស់ទេ តែគាត់បានសុំឲ្យគ្រូពេទ្យ ព្យាយាមធ្វើយ៉ាងណាបញ្ចូលខ្យល់អុកស៊ីហ្សែនសម្រាប់នាង ដើម្បីឲ្យនាងមានដង្ហើមរស់រហូតដល់**ខេមរិទ្ធ**ត្រឡប់មកទាន់។ គ្រូពេទ្យក៏រួសរាន់ ដាក់គ្រឿងជំនួយខ្យល់ដង្ហើមឲ្យនាងរហូតបេះដូងនាងអាចដើរបាន ដូចប្រក្រតីវិញ។

ម៉ោង៨ និង៣០នាទី ខណៈដែលគ្រប់គ្នាស្រក់ទឹកភ្នែកអាណិត**ខេមា** ទូរស័ព្ទរបស់**មាណាវី**ក៏លាន់ឡើង៖

«បង**រិទ្ធ**ទូរស័ព្ទមក!»

*ទោមស្រស់ស្រែកឡើង មុខនាងប្រែជាញញឹម ទាំងទឹកភ្នែកដាមជាប់ថ្ពាល់។ គ្រប់គ្នាងាកមកចាំស្ដាប់នាង ដោយយកចិត្តទុកដាក់ ស្ទើរតែភ្លេចដកដង្ហើម៖*

*«អាឡូ!...»*

*នាងចុចទទួល ហើយបានឮសំឡេងរបស់**ខេមរិទ្ធ** យ៉ាងច្បាស់ក្រឡែត ពីចុងខ្សែម្ខាងទៀត ដោយទឹកសម្ដី បង្កប់ភាពរីករាយជាទីបំផុត៖*

*«អូន**រី**! បងធ្វើបានហើយ! បងធ្វើបានសម្រេចហើយ!!! ហើយបងនឹងក្លាយជាអនុប្រធានគ្រប់គ្រង ផ្នែកទីផ្សារប្រចាំក្រុមហ៊ុនយើង។»*

***មាណវី**ប្រែទឹកមុខ ទឹកភ្នែកនាងស្រក់ប៉ាត់ៗ មិនដឹងចាប់ផ្ដើមនិយាយពីត្រឹមណា៖*

*«បង**រិទ្ធ**!... បងមកដល់ណាហើយ?... បង!?... បងប្រញាប់មកមន្ទីរពេទ្យជាបន្ទាន់ណា... ម៉ាក់កំពុងរង់ចាំបងនៅទីនេះ...»*

***ខេមរិទ្ធ**ចាប់ផ្ដើមសំឡេងក្អួរ តែចិត្តមួយក៏នៅគិតថា **មាណវី**លេងសើចនឹងខ្លួន ទើបតបមកវិញបែបធម្មតាថា៖*

*«អូន**រី**... កំពុងលេងសើច នឹងបងមែនទេ?»*

*«ក្មួយ**រិទ្ធ**! ក្មួយនៅឯណា ជិតមកដល់ហើយនៅ? ម៉ាក់ក្មួយកំពុងចាំណា!»*

*បងប្រុសខេមានិយាយជំនួសវិញ ព្រោះ**មាណវី**ជួលចិត្តពេក នាងអួលណែនពេញដើមទ្រូង មិនដឹងតបទៅ**ខេមរិទ្ធ**វិញយ៉ាងណា?... ពេលបានឮសំឡេងអ៊ំប្រុស **ខេមរិទ្ធ**ក៏ច្បាស់ក្នុងចិត្តថាពិតជាមានរឿងកើតឡើងមែន៖*

*«បាទលោកអ៊ំ! ជិតដល់ភ្នំពេញហើយ... បន្តិចទៀតខ្ញុំនឹងទៅដល់។... លោកពូ បើកលឿនៗឡើង ម៉ាក់ខ្ញុំឈឺនៅមន្ទីរពេទ្យ។»*

***ខេមរិទ្ធ**ដាក់ទូរស័ព្ទចុះ ហើយប្រញាប់តឿន**ករុណា** ឲ្យបន្ថែមល្បឿន។ **មាណវី**ព្យាយាមទូរស័ព្ទត្រឡប់ទៅវិញដែរ តែមិនចូល។ ម្នាក់ៗនាំគ្នាបារម្ភពី**ខេមា**ផង និងខ្វាយខ្វល់ពី**ខេមរិទ្ធ**ផង មិនដឹងថា **ខេមរិទ្ធ**មានរឿងអីកើតឡើងឬអត់។ អ្នកខ្លះ ក៏នាំគ្នាជជែកពីនេះពីនោះ ដើម្បីបន្ធូរបរិយាកាសឲ្យបានធូរស្រាលឡើង។ យប់កាន់តែជ្រៅ ភ្ញៀវដែលមកមើលអាការៈ**ខេមា** ក៏សុំលាទៅផ្ទះ ម្ដងម្នាក់ៗ។ **មាណវី**ក៏ប្រាប់ឲ្យម្ដាយ ត្រឡប់ទៅផ្ទះមុន។ ភ្ញៀវចុងក្រោយដែលលាទៅផ្ទះគឺលោកនាយកក្រុមហ៊ុន ពេលនោះម៉ោងជិត១១យប់ទៅហើយ។ មុននឹងទៅ គាត់ក៏នឹកឃើញថា **ខេមរិទ្ធ**ទៅជាមួយ**ករុណា** ទើបប្រាប់ឲ្យ**មាណវី** ទូរស័ព្ទទៅលេខ**ករុណា**ម្ដង ប៉ុន្តែនៅតែមិនអាចទាក់ទងបានដូចគ្នា។*

កន្ទះម៉ោងក្រោយមក **ខេមរិន្ទ**រត់មកក្នុងមន្ទីរពេទ្យតាមរកម្ដាយ ក៏បានជួប**មាណវី**និងអ៊ំរបស់គេ កំពុងអង្គុយលើកៅអីខាងមុខបន្ទប់មួយៗ **ខេមរិន្ទ**ឈប់ទ្រឹងនៅចំពោះមុខអ្នកទាំងពីរៗ អ្នកកំលោះ ដកដង្ហើមញាប់ស្អេកហត់គឃូរ ភ្នែកក្រហម ហើយមានដក់ទឹកថ្លាពេញប្រឡង់ៗ សំឡេងញ័រៗរបស់គេ ក៏រសាត់ចេញមកៈ

«ចុះម៉ាក់!... ម៉ាក់នៅណា?...»

**មាណវី**សំឡឹងមុខឪពុកមា... បុរសជាបងប្រុសខេមា ក៏ងើបឈរឡើង ហើយទះស្មាក្មួយតិចៗ ជាមួយនឹងសម្ដីស្មើៗៈ

«ម៉ាក់ក្មួយកំពុងរង់ចាំក្មួយនៅក្នុងបន្ទប់... ក្មួយចូលទៅរកគេចុះ!»

**ខេមរិន្ទ**ចូលទៅក្នុងបន្ទប់ ឃើញម្ដាយដេកស្ងួកស្ដឹង ដាក់ខ្យល់អុកស៊ីហ្សែនជាប់ៗ កំលោះចាប់ផ្ដើមស្រោលខ្លួនស្ទើក លុតជង្គង់ព្រូស ចាប់ដៃម្ដាយមកឱបថើប ព្រមជាមួយទឹកភ្នែកៗ **ខេមរិន្ទ**ក្រឡេកឃើញកាដូបីកញ្ចប់ ដាក់នៅលើតុក្បែរនោះៗ លើកញ្ចប់នីមួយៗ មានសេចក្ដីខុសៗគ្នាថា «រីករាយថ្ងៃកំណើតកូន**រិន្ទ**!», «រីករាយថ្ងៃកំណើតកូន**វី**!», និងមួយកញ្ចប់ទៀតសរសេរដោយប៉ារបស់**ខេមរិន្ទ**ថា «ថ្ងៃនេះថ្ងៃ១០ធ្នូ រីករាយថ្ងៃកំណើត**ខេមា**!»ៗ

**ខេមរិន្ទ**យំក្រាបមុខលើគ្រែ... មួយស្របក់មក គេក៏ងើបមុខឡើង ដោយដៃនៅចាប់កាន់ដៃម្ដាយជាប់ៗ នរៈសម្លឹងមើលមុខម្ដាយ ហើយពោលពាក្យចេញ ដោយសំឡេងអួលអាក់ៈ

«រីករាយថ្ងៃកំណើតម៉ាក់!»

ជឿទេ... ថាទឹកមុខរបស់**ខេមា** ដែលញញឹមជាប់រហូតនោះ កាន់តែមើលកាន់តែឃើញថានាងកំពុងមានសេចក្ដីសុខខ្លាំងណាស់ៗ បន្ទាប់ពីនោះបានបន្ដិច ម៉ាស៊ីនវាស់ស្ទង់ចង្វាក់បេះដូងក៏ឲ្យសញ្ញាថា បេះដូងរបស់**ខេមា**ឈប់លោតហើយៗ

ជាការពិតគ្រប់ៗគ្នា ទាំង**ខេមា** បងប្រុសរបស់នាង នាយកក្រុមហ៊ុន និង**ខេមរិន្ទ** សុទ្ធតែដឹងថា នាងធ្លាប់ទៅឲ្យពេទ្យពិនិត្យ ហើយក្រោយពីធ្វើរោគវិនិច្ឆ័យរួចរាល់ បានបង្ហាញថា នាងមានជម្ងឺមហារីកគ្រាប់ឈាមធ្ងន់ធ្ងរៗ តែដោយសារការរក្សាសុខភាព និងដោយសារនាងជាមនុស្សដែលមានសេចក្ដីស្រឡាញ់ ចំពោះគ្រប់អ្វីៗដែលនៅជុំវិញខ្លួននាង ទើបធ្វើឲ្យរយៈពេលកន្លងមក៧ឆ្នាំហើយ ដែលជម្ងឺរបស់នាង មិនបានបញ្ចេញរោគសញ្ញាអ្វីសោះៗ គឺទើបតែថ្ងៃនេះ ថ្ងៃដែលរោគដ៏កាចសាហាវ ចាប់ផ្ដើមឲ្យរោគសញ្ញា ហើយក៏ជាថ្ងៃដែលមច្ចុរាជនេះ ឆក់យកជីវិតនាងទៅជាមួយផងៗ

កាដូ៣កញ្ចប់ ដែល**មាណាវី**យកមកពីផ្ទះ**ខេមា** ហើយយកមកទុកលើតុក្បែរនាង ក្នុងរយៈចុងក្រោយនោះ កាដូ២ជារបស់ដែល**ខេមា**ត្រៀមទុក សម្រាប់**ខេមរិទ្ធ** និង**មាណាវី** ក្នុងថ្ងៃកំណើតថ្ងៃនេះៗ ចំណែកកាដូមួយកញ្ចប់ទៀត ជាកាដូដំបូងបំផុត ដែល**ខេមា**បានទទួលពីប៉ារបស់**ខេមរិទ្ធ** តាំងពីជាង២០ឆ្នាំមុនម្ល៉េះៗ នៅក្នុងកញ្ចប់អំណោយទាំង៣ សុទ្ធសឹងជានាឡិកាដៃ រួមនឹងខ្ទឹមសារ ដែលសរសេរដោយដៃម្ចាស់អំណោយៗ ក្នុងក្រដាសសតូចៗ ដែលបត់ភ្ជាប់នឹងនាឡិកាទាំងនោះ មានសេចក្តីថា៖

*«ផ្តល់ពេលវេលាដល់មនុស្សដែលយើងស្រឡាញ់ ដោយមិនទាមទារពេលវេលានៃសេចក្តីស្រឡាញ់ពីអ្នកនោះវិញ, ហើយជាការប្រសើរ ប្រសិនណាយើងអាច ធ្វើអ្វីដែលយើងចង់ធ្វើនៅថ្ងៃនេះ ដើម្បីចៀសវាងនៅថ្ងៃស្អែក ដែលយើងគ្មានឱកាសនឹងធ្វើ»ៗ*

**ខេមរិទ្ធ**សំណាងល្អ ដែលបាននៅជាមួយម្តាយ ក្នុងនាទីចុងក្រោយ មុនពេលដែលម្តាយអស់ពេលវេលា ដែលនឹងត្រូវផ្តល់សម្រាប់គេទៀតៗ *«តើពេលវេលារបស់យើង ទុកសម្រាប់អ្នកណា? គ្មាននរណាម្នាក់ដឹងថា យើងមានពេលវេលាសល់តិច ឬច្រើនប៉ុណ្ណាឡើយ ប៉ុន្តែកូននឹងប្រើពេលវេលាដែលកូនមាន ផ្តល់សេចក្តីសុខសម្រាប់ខ្លួនឯង និងគ្រប់ៗគ្នាដែលនៅជុំវិញ ដោយស្នាមញញឹម និងភាពកក់ក្តៅ ដូចដែលម៉ាក់ធ្លាប់ផ្តល់ឲ្យគ្រប់ៗគ្នារហូតមក...»*ៗ សេចក្តីខាងលើនេះ **ខេមរិទ្ធ**នឹងសរសេរ ហើយអានរៀងរាល់ថ្ងៃ១០ធ្នូ ដើម្បីជាអំនោយរំឭកខួបម្តាយ ដែលបានកើត និងស្លាប់ ក្នុងថ្ងៃតែមួយៗ

ចង់ដឹងថា ៣ទំព័រដំបូងរបស់សៀវភៅកំណត់ហេតុ ដែល**ខេមរិទ្ធ**បានទទួលជាកាដូក្នុងឱកាសថ្ងៃខួបកំណើត គម្រប់២០ឆ្នាំ សរសេរយ៉ាងម៉េចខ្លះ?

ទំព័រទី១

*«នៅពេលដែលមនុស្សយើងបានជួបអ្វី ដូចសេចក្តីដែលធ្លាប់ប៉ងប្រាថ្នា ស្ទើរពេញមួយជីវិតហើយនោះ យើងនឹងកើតមានថាមពលពិសេសមួយ រួមនឹងសេចក្តីក្លាហានហ៊ានធ្វើនូវអ្វីដែលយើងមិនធ្លាប់គិតសោះថា ខ្លួនឯងអាចធ្វើបានៗ ដូចនៅក្នុងថ្ងៃនេះ **ខេមា**កំពុងរៀបការជាមួយបងមែនទេ?... នៅពេលមានអូន បងនឹងស៊ូទ្រាំរាល់ទុក្ខលំបាកនានា ហើយលះបង់កម្លាំងកាយចិត្ត ញើសឈាម និងសតិបញ្ញា ដើម្បីកសាងគ្រួសារយើង ឲ្យមានពន្លឺសុភមង្គលចាំងចិញ្ចែងចិញ្ចាចជានិច្ចៗ»*

ទំព័រទី២

«សេចក្ដីរីករាយបំផុតរបស់អូន គឺនៅថ្ងៃដែលបងសុំអូនរៀបការ។ ហើយបើសួរថា មានរឿងអ្វី ដែលធ្វើឲ្យអូនរីករាយ ជាងនេះទៅទៀតនោះ? អូនក៏សុំឆ្លើយថា ការដែលមានគ្រួសារប្រកបដោយសុភមង្គល បានទទួលទានអាហាររួមតុជាមួយគ្នារាល់ថ្ងៃ ហើយបានពឹងអាស្រ័យលើអំពើល្អ របស់មនុស្សដែលខ្លួនស្រឡាញ់ នោះគឺជាសេចក្ដីរីករាយមួយទៀតដែលធ្វើឲ្យអូនមានសេចក្ដីសុខ ហើយវាមិនមែនកើតឡើងដោយសារទ្រព្យសម្បត្តិ មាសពេជ្រ ឬមុខមាត់នៅក្នុងសង្គមឡើយ។»

ទំព័រទី៣

«ពួកយើងធ្លាប់គិតថា សេចក្ដីស្រឡាញ់របស់ពួកយើង គឺធំធេងលើសអ្វីៗទាំងអស់, តែសេចក្ដីស្រឡាញ់នោះ បានក្លាយជារបស់តូចតាចភ្លាមៗ នៅពេលដែលពួកយើងដឹងថា យើងស្រឡាញ់កូនប៉ុណ្ណា?...»

សរសេរចប់,ថ្ងៃទី២៨ ឧសភា ២០០៨